ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ០១ ផក

# ផែនការ
# ស្តីពី
# យុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី១០
# រយៈពេល១ឆ្នាំ ចាប់ពីថ្ងៃទី១ ខែមករា ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥

សភាពការណ៍គ្រឿងញៀនរបស់ពិភពលោកនៅតែជាបញ្ហាប្រឈមដ៏ធ្ងន់ធ្ងរមួយមិនទាន់មានភាពធូរស្រាលនៅឡើយដែលសហគមន៍អន្តរជាតិកំពុងប្រមូលផ្តុំយកចិត្តទុកដាក់ដោះស្រាយ។ ការផលិត និងការជួញដូរគ្រឿងញៀនខុសច្បាប់នៅតែបន្តកើតមានឡើងដូចជានៅតំបន់ត្រីកោណមាសនិងនៅតំបន់អឌ្ឍចន្ទមាសជាដើម។ ពួកឧក្រិដ្ឋជនគ្រឿងញៀនតែងតែផ្លាស់ប្តូរយុទ្ធសាស្ត្រនិងប្រើប្រាស់បច្ចេកវិទ្យាទំនើបដើម្បីផលិតគ្រឿងញៀនប្រភេទថ្មីៗដែលកំពុងកើនឡើង និងគេចវេះពីការចាប់ខ្លួន។ ដោយឡែកសភាពការណ៍គ្រឿងញៀននៅកម្ពុជាក៏នៅតែមាននិន្នាការមិនទាន់ថមថយនៅឡើយ ដោយក្នុងនោះ ការប្រើប្រាស់ ការចែកចាយ ការជួញដូរ និងការកែច្នៃផលិតគ្រឿងញៀន នៅតែបន្តកើតមានក្នុងសង្គមកម្ពុជា។

ក្នុងគោលបំណងទប់ស្កាត់និងឈានទៅលុបបំបាត់ឥទ្ធិពលប្រកបដោយគ្រោះថ្នាក់នៃឧក្រិដ្ឋកម្មគ្រឿងញៀន រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវផែនការស្តីពីយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ជាបន្តបន្ទាប់ដែលគិតត្រឹមឆ្នាំ២០២៤កន្លងទៅ មានចំនួន៩លើកមកហើយ សំដៅជំរុញនិងកៀរគរ គ្រប់ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងវិស័យឯកជន ព្រមទាំងបំផុសប្រជាពលរដ្ឋចូលរួមទាំងអស់គ្នា ដើម្បីក្លាយជាចលនាជាតិមួយក្នុងស្មារតីទទួលខុសត្រូវរួមពីគ្រប់វិស័យទាំងអស់។

ផែនការស្តីពីយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ទាំង៩លើកកន្លងមក (២០១៧-២០២៤) អាជ្ញាធរមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់បានអនុវត្តនិងបំពេញតួនាទីយ៉ាងសកម្មលើកិច្ចការសំខាន់ៗមួយចំនួន (១) ជំរុញការផ្សព្វផ្សាយអប់រំយ៉ាងផុលផុស តាមគ្រប់មធ្យោបាយ គ្រប់រូបភាព និងដល់ទីកន្លែងសរុបចំនួន **៧៥៦ ៩៣៤ លើក** ដែលមានអ្នកចូលរួមនិងទទួលសារអប់រំក្នុងម្នាក់អាចទទួលសារអប់រំលើសពីម្តង (តួលេខបូកយោងសរុបចំនួន **៣២ ៨៥៥ ២២៤ អង្គ/នាក់**)។ ជាពិសេសក្នុងឆ្នាំ២០២៤កន្លងមកនេះ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនបានសហការរៀបចំការប្រកួតកីឡាបាល់ទាត់មិត្តភាពក្រោមមូលបទ «រួមគ្នាដើម្បីសប្បុរសធម៌ និងប្រយុទ្ធប្រឆាំងគ្រឿងញៀន» ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា និងវេទិកាផ្សព្វផ្សាយអប់រំបញ្ហាគ្រឿងញៀនដ៏ធំមួយគឺ «ទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ២៦ មិថុនា ២០២៤» ដែលត្រូវបានការិយាល័យអង្គការសហប្រជាជាតិទទួលបន្ទុកគ្រឿងញៀន

និងបទឧក្រិដ្ឋ (UNODC) ទទួលស្គាល់និងកោតសរសើរចំពោះកម្ពុជាជាប្រទេសគំរូ ក្នុងការរៀបចំទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងការបង្កើតកម្មវិធីទូរស័ព្ទដៃ **NoDrug** ជាដើម (២) ជំរុញការអនុវត្តវិធានការរដ្ឋបាល និងវិធានការច្បាប់ ដោយបានបិទទីតាំងអាជីវកម្មសរុបចំនួន **៤៨ កន្លែង** និងបានបើកប្រតិបត្តិការបង្ក្រាបបទល្មើសគ្រឿងញៀនដោយឃាត់ខ្លួនជនសង្ស័យជាច្រើនម៉ឺននាក់ និងចាប់យកគ្រឿងញៀនគ្រប់ប្រភេទមានទម្ងន់ប្រមាណ **៤២ ៨៤៨ គីឡូក្រាម** និងសារធាតុគីមីផ្សំប្រមាណ **៥៩៦ ៣៩៩ គីឡូក្រាម** រួមទាំងរឹបអូសមធ្យោបាយសម្ភារៈ និងវត្ថុតាង ទ្រព្យសម្បត្តិ និងបង្កកអចលនទ្រព្យជាច្រើនកន្លែង។ ក្នុងនោះសមត្ថកិច្ចបានស្រាវជ្រាវរកឃើញ និងបង្ក្រាបបទល្មើសគ្រឿងញៀនដែលមានអង្គការចាត់តាំងចំនួន **៦២៧ ករណី** ឃាត់ខ្លួនឧក្រិដ្ឋជនមេខ្លោង **១៩៥ នាក់** និងបណ្ដាញខ្សែរយៈ **១ ៤៥៣ នាក់** កសាងសំណុំរឿងបញ្ជូនទៅតុលាការ ដើម្បីផ្ដន្ទាទោសតាមច្បាប់ (៣) បានបញ្ជូនអ្នកញៀនគ្រឿងញៀនទៅទទួលការព្យាបាលនិងស្ដារនីតិសម្បទាសរុបចំនួន **១៤៥ ៧៩០ នាក់** បានធ្វើសមាហរណកម្មចូលក្នុងគ្រួសារនិងសហគមន៍វិញសរុបចំនួន **៨១ ៦៧៥ នាក់។**

ទោះបីជាប្រតិបត្តិការប្រយុទ្ធប្រឆាំងបទល្មើសគ្រឿងញៀនខុសច្បាប់ទទួលបានលទ្ធផលជាវិជ្ជមានដូចបានរៀបរាប់ខាងលើនោះក្ដី យើងបានពិនិត្យឃើញបញ្ហាប្រឈមថ្មីមួយចំនួនដែលបានកើតឡើង ដូចជា ការប្រើប្រាស់ល្បិចកលនាំចូលនូវសារធាតុគីមីបម្រើឱ្យវិស័យកសិកម្ម ឧស្សាហកម្ម បន្លំយកមកកែច្នៃផលិតជាសារធាតុញៀនសំយោគ ការផ្លាស់ប្ដូរច្រក និងផ្លូវចរាចរ រួមទាំងរូបភាពនៃការនាំចូលឆ្លងកាត់ ការកែច្នៃផលិតជាដើម។ ក្ដីបារម្ភដែលជាបញ្ហាប្រឈមកុំរ៉េ និងកំពុងបង្កហានិភ័យដល់សង្គមជាតិនោះគឺ ការប្រើប្រាស់គ្រឿងញៀននៅតាមសហគមន៍នៅតែបន្តកើតមាននៅឡើយ និងកំពុងតែទាមទារឱ្យចាត់វិធានការជាអាទិភាព ដើម្បីដោះស្រាយប្រកបដោយប្រសិទ្ធភាពបានទាន់ពេលវេលា។

ដោយពិនិត្យឃើញថា មហន្តរាយដែលបណ្ដាលមកពីឧក្រិដ្ឋកម្មគ្រឿងញៀន នៅតែបន្តរីករាលដាលទាំងនៅក្នុងតំបន់និងលើពិភពលោក រួមទាំងព្រះរាជាណាចក្រកម្ពុជាផងនោះ រាជរដ្ឋាភិបាលកម្ពុជាសម្រេចបន្តដាក់ចេញនូវ **ផែនការស្ដីពីយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី១០ ឆ្នាំ២០២៥** ក្នុងគោលដៅដើម្បីបន្តកិច្ចខិតខំប្រឹងប្រែងរួមគ្នាក្នុងការកាត់បន្ថយផលប៉ះពាល់អវិជ្ជមាននៃគ្រឿងញៀនព្រមទាំងកសាងសង្គមដែលមានសុខុមាលភាពនិងសុវត្ថិភាពសម្រាប់ប្រជាពលរដ្ឋគ្រប់រូប ព្រមទាំងការពារកិត្តិយស កិត្យានុភាពជាតិ ដោយបានកំណត់នូវគោលការណ៍និងវិធានការសំខាន់ៗដូចខាងក្រោម៖

## I. គោលការណ៍រួម

- ខិតខំបញ្ចៀសឱ្យបាន មិនឱ្យប្រទេសកម្ពុជាក្លាយជាគោលដៅនៃការប្រព្រឹត្តបទល្មើសគ្រឿងញៀន និងមិនឱ្យឥទ្ធិពលដ៏សាហាវនៃគ្រឿងញៀន ញាំញីបំផ្លិចបំផ្លាញសង្គមជាតិ ជាពិសេសការលើកកម្ពស់សមត្ថភាពក្នុងការចាត់វិធានការបង្ការ ទប់ស្កាត់ និងបង្ក្រាបឱ្យមានប្រសិទ្ធភាពខ្ពស់ ដើម្បីឆ្លើយតបការប្ដេជ្ញាចិត្តថា **កម្ពុជាគឺជាប្រទេសគ្មានគ្រឿងញៀន ដោយផ្ដើមចេញពីបុគ្គលម្នាក់ទៅគ្រួសារមួយដែលស្អាតស្អំគ្មានគ្រឿងញៀន** ស្របតាមទស្សនវិស័យ **«ចូលរួមទាំងអស់គ្នា ដើម្បីជីវិត និងសហគមន៍គ្មានគ្រឿងញៀន»**

- ជំរុញបន្តអនុវត្តបទបញ្ជារបស់រាជរដ្ឋាភិបាលលេខ០១ បប ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២៤ ស្ដីពីការដាក់ចេញវិធានការម៉ឹងម៉ាត់ក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់នៅតាមក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ សំដៅបង្កើននូវជំនឿទុកចិត្ត ប្រសិទ្ធភាពការងារ និងអភិបាលកិច្ចល្អក្នុងស្ថាប័នរដ្ឋ ទាំងថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងក្នុងជួរកងកម្លាំងប្រដាប់អាវុធ រួមទាំងមន្ត្រីរាជការស៊ីវិល

- ជំរុញសកម្មភាពបោសសម្អាតការប្រើប្រាស់គ្រឿងញៀន និងឈានទៅលុបបំបាត់ទីផ្សារគ្រឿងញៀនក្នុងផ្ទៃប្រទេស តាមគោលការណ៍ **«សម្អាតចកចេញពីផ្ទៃបឹង និងរក្សាផ្ទៃបឹងឱ្យថ្លាជាប្រចាំ»** ស្របតាមទិសស្លោក **«៣កុំ ១រាយការណ៍: កុំពាក់ព័ន្ធ កុំអន្តរាគមន៍ កុំលើកលែង និងរាយការណ៍គ្រប់បទល្មើសគ្រឿងញៀន»** ព្រមទាំងបន្តជំរុញការអនុវត្តគោលនយោបាយ **«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»** ឱ្យកាន់តែសកម្មផុលផុស

- បន្តជំរុញការអនុវត្តទិសដៅការងារអាទិភាពប្រយុទ្ធប្រឆាំងគ្រឿងញៀនរបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនរួមមាន (១) ការងារផ្សព្វផ្សាយអប់រំ (២) ការពង្រឹងយន្តការគ្រប់គ្រងសារធាតុគីមីផ្សំ (៣) ការទប់ស្កាត់ការនាំចូលគ្រឿងញៀន (៤) ការទប់ស្កាត់ការកែច្នៃផលិតគ្រឿងញៀន និង(៥) ការលុបបំបាត់ការប្រើប្រាស់ និងការជួញដូរគ្រឿងញៀន

- ពង្រឹងយន្តការឆ្លើយតបទាន់ហេតុការណ៍ ដោយលើកកម្ពស់ប្រសិទ្ធភាពកម្មវិធីទូរស័ព្ទដៃ NoDrug និងប្រព័ន្ធទូរស័ព្ទ Hotline ដើម្បីទទួលព័ត៌មានពីប្រជាពលរដ្ឋពាក់ព័ន្ធនឹងគ្រឿងញៀន និងចាត់វិធានការដោះស្រាយអន្តរាគមន៍ និងបង្ក្រាបឱ្យបានទាន់ពេលវេលា

- ខិតខំប្រមូលផ្តុំលើកកម្ពស់សមត្ថភាព លទ្ធភាពគ្រប់គ្រង ព្យាបាល ស្តារនីតិសម្បទា និងសមាហរណកម្មអ្នកញៀនគ្រឿងញៀនឱ្យបានល្អប្រសើរថែមទៀត ដើម្បីទប់ស្កាត់ការរីករាលដាលការប្រើប្រាស់គ្រឿងញៀនសំដៅរួមចំណែកលុបបំបាត់ទីផ្សារគ្រឿងញៀន និងកាត់បន្ថយបទល្មើសផ្សេងៗ ដែលបណ្តាលមកពីការទទួលរងឥទ្ធិពលពីគ្រឿងញៀន

- លើកកម្ពស់សមត្ថភាពបំពេញការងាររបស់មន្ត្រីអនុវត្តច្បាប់ ទាំងលើវិស័យជំនាញ នីតិវិធី និងក្រមសីលធម៌វិជ្ជាជីវៈ ព្រមទាំងត្រូវបង្កើនកិច្ចសហការល្អជាមួយស្ថាប័នអយ្យការ និងតុលាការ ដើម្បីរួមគ្នាពង្រឹងប្រសិទ្ធភាពក្នុងការកសាងសំណុំរឿងដាក់ស្លានទម្ងន់ទោស សំដៅផ្តន្ទាទោសដល់ពួកឧក្រិដ្ឋជនគ្រឿងញៀនឱ្យបានម៉ឺងម៉ាត់ស្របតាមច្បាប់

- ពង្រឹងនិងពង្រីកវិសាលភាពសហប្រតិបត្តិការឱ្យបានទូលំទូលាយ ជាមួយបណ្តាអង្គការជាតិ អន្តរជាតិស្ថាប័នអនុវត្តច្បាប់បរទេសជាដៃគូ ក្នុងការផ្លាស់ប្តូរព័ត៌មានបម្រើឱ្យវិធានការបង្ការ ទប់ស្កាត់ពីចម្ងាយ និងបណ្តាព័ត៌មាន បទពិសោធល្អៗបម្រើឱ្យការបង្ក្រាប ព្រមទាំងការជួយឧបត្ថម្ភគាំទ្រទាំងស្មារតី បច្ចេកទេស និងសម្ភារៈ

- ខិតខំយកចិត្តទុកដាក់ពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការស្រាវជ្រាវបទល្មើសសម្អាតប្រាក់ ដែលពាក់ព័ន្ធនឹងគ្រឿងញៀន ដើម្បីកាត់ផ្តាច់ចរន្តហិរញ្ញវត្ថុផ្គត់ផ្គង់ដល់សកម្មភាពរបស់ក្រុមឧក្រិដ្ឋជនគ្រឿងញៀន។

## II. វិធានការជាក់ស្តែង

### ១. វិធានការអប់រំ

- អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន មានតួនាទីស្នូលក្នុងការផ្សព្វផ្សាយអប់រំឱ្យមានលក្ខណៈទាក់ទាញនិងទាន់សម័យតាមប្រព័ន្ធបច្ចេកវិទ្យាតាមគ្រប់ទម្រង់និងរូបភាព ដោយបំផុសការយល់ដឹងពីផលប៉ះពាល់នៃគ្រឿងញៀននិងជំរុញការផ្សព្វផ្សាយដើម្បីឱ្យប្រជាពលរដ្ឋទាញយកនិងប្រើប្រាស់កម្មវិធីទូរស័ព្ទដៃ NoDrug ឱ្យកាន់តែច្រើនឡើងៗ សំដៅឱ្យមហាជនទទួលបានសារអប់រំនិងចូលរួមផ្តល់ព័ត៌មាននានាពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន។ ទន្ទឹមនោះ ត្រូវបង្កើតមាតិកាអប់រំឱ្យបានច្រើន និងកម្មវិធីទាក់ទាញនានា ដើម្បីប្រមូលបានការគាំទ្រពីមហាជនក្នុងការប្រើប្រាស់កម្មវិធីទូរស័ព្ទដៃ NoDrug នេះ ព្រមទាំងតាមរយៈមធ្យោបាយផ្សេងៗ ដូចជា បដា ប៉ាណូ ខិត្តប័ណ្ណ លើវិក្កយបត្រប្រើប្រាស់ទឹក ភ្លើង និងលើផលិតផលផ្សេងៗ

- ក្រសួងព័ត៌មាន ត្រូវរៀបចំក្រុមការងារវេទិកាតុមូល ដើម្បីធ្វើការអប់រំខ្លឹមសារប្រយុទ្ធប្រឆាំងគ្រឿងញៀន តាមកម្មវិធីទូរទស្សន៍ វិទ្យុ និងបណ្ដាញផ្សព្វផ្សាយសង្គម ដោយត្រូវកំណត់ឱ្យស្ថានីយទូរទស្សន៍ វិទ្យុ និងបណ្ដាញផ្សព្វផ្សាយព័ត៌មានសង្គម បង្កើតនូវកម្មវិធីផ្សាយជាក់លាក់ ដើម្បីអប់រំប្រចាំថ្ងៃជាពិសេសផលិតឃ្លីបវីដេអូអប់រំខ្លីពាក់ព័ន្ធនឹងខ្សែជីវិតពិតនៃជនរងគ្រោះដោយសារគ្រឿងញៀន និងវិនាសកម្មដល់ក្រុមគ្រួសារ និងសង្គមជាតិ

- ក្រសួងអប់រំ យុវជន និងកីឡា ត្រូវពង្រឹងនិងពង្រីកសកម្មភាពអប់រំប្រឆាំងគ្រឿងញៀនជាប្រចាំ សម្រាប់ឱ្យសិស្សានុសិស្សរៀនសូត្រនៅតាមគ្រប់កម្រិត គ្រប់គ្រឹះស្ថានសិក្សា ស្របតាមកម្មវិធីនៃកម្រិតសិក្សានីមួយៗ និងបញ្ជ្រាបទៅដល់កីឡាករកីឡាការិនីផងដែរ

- ក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ត្រូវរៀបចំកម្មវិធីអប់រំប្រយុទ្ធប្រឆាំងគ្រឿងញៀន ដល់កម្មករ កម្មការិនី នៅតាមរោងចក្រ សហគ្រាស សិប្បកម្ម និងការដ្ឋានសំណង់នានា

- ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ត្រូវធ្វើការណែនាំដល់ក្រុមហ៊ុនទូរស័ព្ទផ្ញើសារអប់រំប្រយុទ្ធប្រឆាំងគ្រឿងញៀន ដល់អ្នកប្រើប្រាស់ឱ្យបានញឹកញាប់ជាប់ជាប្រចាំ

- ក្រសួងទេសចរណ៍ ត្រូវណែនាំឱ្យម្ចាស់ ឬអ្នកគ្រប់គ្រងគោលដៅដែលពាក់ព័ន្ធនឹងវិស័យទេសចរណ៍ រួមទាំងកន្លែងកម្សាន្តសប្បាយនានា ត្រូវតាំង បិតនូវខ្លឹមសារអប់រំ និង/ឬការហាមចរាចរ ជួញដូរ ប្រើប្រាស់គ្រឿងញៀន

- ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ត្រូវរៀបចំមាតិកា សារអប់រំ ឃ្លីបវីដេអូខ្លី ព្រឹត្តិការណ៍ប្រគំតន្ត្រី ដើម្បីឱ្យសិល្បករ សិល្បការិនី ចូលរួមសម្ដែងនិងផ្សព្វផ្សាយអប់រំពាក់ព័ន្ធនឹងផលប៉ះពាល់និងវិនាសកម្មដោយសារគ្រឿងញៀន

- ក្រសួងធម្មការនិងសាសនា ត្រូវរៀបចំឱ្យមានកម្មវិធី បញ្ជ្រាបខ្លឹមសារអប់រំប្រយុទ្ធប្រឆាំងគ្រឿងញៀន តាមរយៈកម្មវិធីសាសនា ទាំងពុទ្ធសាសនា គ្រឹស្តសាសនា ឥស្លាមសាសនា និងសាសនាដទៃទៀត

- គណៈបញ្ជាការឯកភាពរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងក្រុមការងារថ្នាក់ជាតិគ្រប់ថ្នាក់ ត្រូវរៀបចំឱ្យមានព្រឹត្តិការណ៍ផ្សព្វផ្សាយអប់រំប្រយុទ្ធប្រឆាំងគ្រឿងញៀន ក្នុងដែនសមត្ថកិច្ចរបស់ខ្លួនឱ្យបានញឹកញាប់និងឱ្យអស់ពីលទ្ធភាព (មួយកន្លែងឱ្យបានយ៉ាងតិច២លើកក្នុងមួយខែ) តាមរយៈវេទិកាសាធារណៈ វេទិកាផ្សព្វផ្សាយគោលនយោបាយ **«ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»** ឬវេទិកាផ្សេងៗទៀត។

## ២. វិធានការរដ្ឋបាល

គណៈបញ្ជាការឯកភាពរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលឃុំ សង្កាត់ ក្នុងដែនសមត្ថកិច្ចរបស់ខ្លួនត្រូវ៖

-ធ្វើបច្ចុប្បន្នភាពបញ្ជីគោលដៅដែលងាយរងផលប៉ះពាល់ដោយសារគ្រឿងញៀន និងត្រូវកោះអញ្ជើញម្ចាស់ទីតាំងឬអ្នកគ្រប់គ្រងអាជីវកម្មទាំងនោះ មកធ្វើការពន្យល់ណែនាំឱ្យយកចិត្តទុកដាក់ក្នុងការងារគ្រប់គ្រងឱ្យបានហ្មត់ចត់ ព្រមទាំងធ្វើកិច្ចសន្យាសហការបង្ការ ទប់ស្កាត់មិនឱ្យកើតមានបទល្មើសគ្រឿងញៀននៅក្នុងទីតាំងរបស់ខ្លួន

-ដឹកនាំកម្លាំងរដ្ឋបាលក្នុងមូលដ្ឋាន ជាពិសេសកន្លែងមិនទាន់រៀបរយផ្សេងៗរួមទាំងក្នុងក្លឹបកម្សាន្ត ខុនដូ បារ KTV ផ្ទះសំណាក់ ដោយត្រូវធ្វើការតាមដាន ត្រួតពិនិត្យ និងចាត់វិធានការម៉ឺងម៉ាត់ ដាច់ខាត ដើម្បីបិទ ឬដកហូតអាជ្ញាបណ្ណអនុញ្ញាតធ្វើអាជីវកម្មជាបណ្ដោះអាសន្នឬជាស្ថាពរ ចំពោះទីតាំងអាជីវកម្មណាដែលបណ្ដែតបណ្ដោយឱ្យមានសកម្មភាពជួញដូរនិងប្រើប្រាស់គ្រឿងញៀន

-មានកិច្ចប្រជុំពិគ្រោះយោបល់ជាមួយសហគមន៍ គ្រឹះស្ថានសិក្សា គ្រឹះស្ថានសាធារណៈ រោងចក្រ សហគ្រាស និងវិស័យឯកជននានា ដើម្បីប្រមូលផ្តុំកិច្ចសហការក្នុងការបង្ការ ទប់ស្កាត់បទល្មើសគ្រឿងញៀន ឬអនុវត្តវិធានការរដ្ឋបាល។

ដោយឡែក អគ្គនាយកដ្ឋានពន្ធនាគារត្រូវបន្តយកចិត្តទុកដាក់ក្នុងការគ្រប់គ្រងពន្ធនាគារនិងមណ្ឌលអប់រំកែប្រែឱ្យបានម៉ឺងម៉ាត់ ហ្មត់ចត់ ប្រកបដោយស្មារតីប្រុងប្រយ័ត្ននិងទទួលខុសត្រូវខ្ពស់ ដោយមិនត្រូវឱ្យមានការលួចនាំចូលគ្រឿងញៀនផ្តល់ឱ្យពិរុទ្ធជនឬទណ្ឌិត និង/ឬមានទំនាក់ទំនងពីក្នុងពន្ធនាគារចេញមកខាងក្រៅពាក់ពន្ធ័នឹងបទល្មើសគ្រឿងញៀន។ ជាមួយគ្នានោះ ត្រូវពិចារណាលើវិធានការក្នុងការគ្រប់គ្រងជនល្មើសដែលពាក់ព័ន្ធនឹងគ្រឿងញៀនឬសេពគ្រឿងញៀន ដាច់ដោយឡែកពីទណ្ឌិតឬពិរុទ្ធជនដទៃទៀត។

## ៣. វិធានការព្យាបាល ស្តារនីតិសម្បទា និងសមាហរណកម្ម

- អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ត្រូវសម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីលើកទឹកចិត្តនិងគាំទ្រ ដើម្បីធានានិរន្តរភាពនៃកិច្ចដំណើរការរបស់មជ្ឈមណ្ឌលរដ្ឋ ឯកជន និងអង្គការមិនមែនរដ្ឋាភិបាល ព្រមទាំងគិតគូរបង្កើតប្រព័ន្ធទិន្នន័យបែបឌីជីថលដើម្បីតាមដាននិងគ្រប់គ្រងអ្នកញៀនគ្រឿងញៀនឱ្យមានភាពច្បាស់លាស់ នៅតាមមជ្ឈមណ្ឌលជាតិនិងមណ្ឌលព្យាបាលនិងស្តារនីតិសម្បទារបស់រដ្ឋ ឯកជន និងអង្គការមិនមែនរដ្ឋាភិបាល និងនៅពេលធ្វើសមាហរណកម្មចូលក្នុងសហគមន៍វិញ

- ក្រសួងសុខាភិបាល ត្រូវខិតខំលើកកម្ពស់សមត្ថភាព វិជ្ជាជីវៈក្នុងការបន្សាបនិងព្យាបាល ព្រមទាំងពង្រីកសេវាបន្សាប ព្យាបាលដោយផ្អែកលើសហគមន៍ នៅតាមមណ្ឌលសុខភាពនិងមន្ទីរពេទ្យបង្អែក ដើម្បីចូលរួមចំណែកកាត់បន្ថយការរីករាលដាលនៃការប្រើប្រាស់គ្រឿងញៀននៅតាមមូលដ្ឋាន

- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវពង្រឹងនិងពង្រីកសមត្ថភាពមជ្ឈមណ្ឌលជាតិ ព្រមទាំងមណ្ឌលបណ្តោះអាសន្នសម្រាប់អប់រំ បន្សាប ព្យាបាល និងស្តារនីតិសម្បទារបស់រដ្ឋបន្ថែមទៀត ដើម្បីត្រៀមទទួលជនរងគ្រោះ ដែលប្រមូលបានឬរកឃើញតាមរយៈការអនុវត្តវិធានការរដ្ឋបាលនិងវិធានការច្បាប់ក្នុងយុទ្ធនាការនេះ និង/ឬតាមការស្នើសុំដោយស្ម័គ្រចិត្តពីសំណាក់ក្រុមគ្រួសារនិងជនរងគ្រោះ

- ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវផ្តល់ការបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីជួយជនដែលញៀនគ្រឿងញៀន ក្នុងការស្វែងរកការងារធ្វើក្រោយចាកចេញពីមជ្ឈមណ្ឌលស្តារនីតិសម្បទា

-គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលឃុំ សង្កាត់ ត្រូវយកចិត្តទុកដាក់រៀបចំឱ្យមានយន្តការគ្រប់គ្រងអ្នកប្រើប្រាស់គ្រឿងញៀន ដោយត្រូវប្រមូលទិន្នន័យឱ្យបានច្បាស់លាស់អំពីមុខសញ្ញាប្រើប្រាស់ និងងាយរងផលប៉ះពាល់ដោយសារគ្រឿងញៀន។ ទន្ទឹមគ្នានោះ ត្រូវជំរុញនិងលើកទឹកចិត្តអ្នកដែលមិនទាន់ទទួលបានការព្យាបាល ឱ្យទៅទទួលយកការព្យាបាល និងត្រូវចាត់វិធានការតាមដានគ្រប់គ្រងចំពោះបុគ្គលដែលបានធ្វើសមាហរណកម្មចូលក្នុងសហគមន៍ បន្ទាប់ពីចាកចេញពីមណ្ឌលព្យាបាល និងស្តារនីតិសម្បទា ដើម្បីបង្ការ ទប់ស្កាត់កុំឱ្យវិលត្រឡប់ទៅសេពគ្រឿងញៀនវិញ

- គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត ត្រូវពិនិត្យលទ្ធភាព និងលើកសំណើដើម្បីបង្កើតនូវមណ្ឌលបណ្តោះអាសន្នសម្រាប់អប់រំ បន្សាប ព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន នៅមូលដ្ឋានរបស់ខ្លួន

- អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ត្រូវសហការជាមួយក្រសួង ស្ថាប័នជំនាញពាក់ព័ន្ធ និងគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ដើម្បីបង្កលក្ខណសម្បត្តិលើកទឹកចិត្តដល់វិស័យឯកជនចូលរួម និង/ឬកសាងមណ្ឌលបណ្តោះអាសន្នសម្រាប់បន្សាប ព្យាបាលអ្នកញៀនគ្រឿងញៀន។

## ៤. វិធានការអនុវត្តច្បាប់

គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលឃុំ សង្កាត់ ត្រូវដឹកនាំកម្លាំងអនុវត្តច្បាប់និងកងកម្លាំងមានសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីចាត់វិធានការម៉ឺងម៉ាត់ក្នុងការស្វែងរកឱ្យឃើញ និងទប់ស្កាត់ការលួចលាក់នាំចូលគ្រឿងញៀនខុសច្បាប់ឆ្លងកាត់ព្រំដែនចូលមកក្នុងភូមិសាស្ត្រខេត្តរបស់ខ្លួនឬឆ្លងកាត់ពីខេត្តមួយទៅខេត្តមួយទៀត និងត្រូវបំពេញតួនាទីឱ្យសកម្មថែមទៀត ដើម្បីដោះស្រាយចំពោះការរាយការណ៍ពីប្រជាពលរដ្ឋពាក់ព័ន្ធនឹងគ្រឿងញៀនតាមប្រព័ន្ធកម្មវិធីទូរស័ព្ទដៃ NoDrug ឱ្យបានទាន់ពេលវេលានិងមានប្រសិទ្ធភាព ដោយត្រូវយកចិត្តទុកដាក់៖

- បើកយុទ្ធនាការជាប្រចាំបោសសម្អាតបណ្ដាញឧក្រិដ្ឋជនជួញដូរគ្រឿងញៀនជាក្រុមតូចៗ និងត្រូវអនុវត្តវិធានការច្បាប់យ៉ាងម៉ឺងម៉ាត់បំផុត ដោយត្រូវបន្តស្រាវជ្រាវរកប្រភពនៃគ្រឿងញៀន និងក្រុមមេខ្លោងបណ្ដាញខ្សែរយៈ ដើម្បីបំផ្លាញឱ្យដល់ឫសគល់។ ក្នុងករណីចាំបាច់ ត្រូវស្នើសុំកិច្ចសហការជាមួយមន្ទីរប្រឆាំងគ្រឿងញៀននៃអគ្គស្នងការដ្ឋាននគរបាលជាតិ ដើម្បីបើកករណីតស៊ូ ស្រាវជ្រាវ ស្វែងរក និងបង្ក្រាបមេខ្លោងព្រមទាំងបណ្ដាញខ្សែរយៈជួញដូរគ្រឿងញៀនឆ្លងដែន

- បើកយុទ្ធនាការជាប្រចាំបោសសម្អាតអ្នកប្រើប្រាស់គ្រឿងញៀន តាមរយៈការសហការផ្ដល់ព័ត៌មានពីអាណាព្យាបាល គ្រឹះស្ថានសិក្សា ឬសហគមន៍ ដើម្បីធ្វើការអប់រំ បន្សាប ព្យាបាលនៅតាមសហគមន៍ (ករណីស្រាល) ឬបញ្ជូនទៅមណ្ឌលបន្សាប ព្យាបាល និងស្ដារនីតិសម្បទា (ករណីធ្ងន់ធ្ងរ) និងករណីចាំបាច់អនុវត្តវិធានការដាក់ទណ្ឌកម្មក្រោម **៤៨ ម៉ោង** ដោយឱ្យធ្វើការងារហត្ថកម្មឬការងារអនាម័យនៅតាមទីសាធារណៈ

- តាមដាន គ្រប់គ្រង និងបង្ក្រាបឱ្យបានម៉ឺងម៉ាត់នូវសកម្មភាពកែច្នៃផលិតគ្រឿងញៀនសំយោគ ការដាំដុះ ការចម្រាញ់ ការនាំចូលវត្ថុធាតុដើមជាសារធាតុគីមីផ្សំដែលអាចកែច្នៃផលិតគ្រឿងញៀនសំយោគ ដែលកើតមាននៅក្នុងដែនសមត្ថកិច្ចទទួលខុសត្រូវរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

- ធ្វើជាអ្នកសម្របសម្រួល ដើម្បីជំរុញកិច្ចពិគ្រោះពិភាក្សារវាងស្ថាប័នអយ្យការ តុលាការ ជាមួយអង្គភាពនគរបាល និងកងរាជអាវុធហត្ថ ដើម្បីធ្វើឱ្យកិច្ចសហការកាន់តែមានដំណើរការរលូន លុបបំបាត់និទណ្ឌភាព និងរិះរកវិធីកសាងសំណុំរឿងឱ្យបានរឹងមាំ ដើម្បីធានាដល់ការផ្ដន្ទាទោសមេខ្លោងនិងបណ្ដាញជួញដូរគ្រឿងញៀន។

ចំពោះគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ដែលមានការិយាល័យទំនាក់ទំនងព្រំដែន (BLO) ត្រូវសហការជាមួយមន្ទីរប្រឆាំងគ្រឿងញៀននៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន រៀបចំកិច្ចប្រជុំត្រួតពិនិត្យក្នុងមួយខែម្ដងជាមួយប្រធាននិងមន្ត្រីការិយាល័យទំនាក់ទំនងព្រំដែន (BLO) ដើម្បីជំរុញលើកទឹកចិត្តឱ្យមានកិច្ចសហការរួមគ្នាក្នុងការផ្ដល់ព័ត៌មាន និងផ្លាស់ប្ដូរសភាពការណ៍ជាប់ជាប្រចាំ។

រដ្ឋបាលខេត្តជាប់ព្រំដែនកម្ពុជា-ឡាវ កម្ពុជា-ថៃ កម្ពុជា-វៀតណាមត្រូវខិតខំសហការ ជាមួយភាគីឡាវ ភាគីថៃ ភាគីវៀតណាម ដើម្បីផ្លាស់ប្ដូរព័ត៌មាន និងសហការស៊ើបអង្កេតរកមុខសញ្ញា ឈានទៅបង្ការ ទប់ស្កាត់ និងកាត់ផ្ដាច់ការចរាចរគ្រឿងញៀនឆ្លងកាត់តាមព្រំដែន។

ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវពង្រឹងការអនុវត្តនិយាមនីតិវិធីប្រតិបត្តិ (SOP) ស្ដីពីការគ្រប់គ្រងត្រួតពិនិត្យសារធាតុញៀននិងសារធាតុគីមីផ្សំឱ្យមានប្រសិទ្ធភាព។

អគ្គស្នងការដ្ឋាននគរបាលជាតិ ត្រូវខិតខំបង្កើនប្រតិបត្តិការស្រាវជ្រាវ ស៊ើបអង្កេត និងបង្ក្រាបបទល្មើសគ្រឿងញៀនដែលមានលក្ខណៈជាអង្គការចាត់តាំង ព្រមទាំងបង្កើនកិច្ចសហការជាមួយក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធទាំងក្នុងនិងក្រៅប្រទេស ដើម្បីពន្លាតនីតិវិធីប្រឆាំងការសម្អាតប្រាក់។

### ៥. វិធានការអនុវត្តបទបញ្ជារបស់រាជរដ្ឋាភិបាលលេខ០១ បប

ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបន្តជំរុញការអនុវត្តបទបញ្ជារបស់រាជរដ្ឋាភិបាលលេខ០១ បប ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការដាក់ចេញវិធានការម៉ឺងម៉ាត់ក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ នៅតាមក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ឱ្យបានជាប់ជាប្រចាំក្នុងគោលបំណងលើកកម្ពស់ជំនឿទុកចិត្ត ប្រសិទ្ធភាពការងារ និងអភិបាលកិច្ចល្អ ព្រមទាំងពង្រឹងគុណភាពធនធានមនុស្សប្រកបដោយភាពស្អាតស្អំនិងភាពជាគំរូក្នុងស្ថាប័នរដ្ឋទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។

ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវចាត់វិធានការច្បាប់និងអប់រំឱ្យបានម៉ឺងម៉ាត់ ដោយគ្មានការលើកលែងចំពោះមន្ត្រីទាំងឡាយណាដែលមានការប្រើប្រាស់និងពាក់ព័ន្ធនឹងគ្រឿងញៀនខុសច្បាប់។ ត្រូវណែនាំនិងលើកទឹកចិត្តពួកគាត់ឱ្យទៅទទួលសេវាព្យាបាល បន្សាប និងស្តារនីតិសម្បទានៅមជ្ឈមណ្ឌលនិងមណ្ឌលទាំងរដ្ឋនិងឯកជន ដើម្បីអាចមានឱកាសធ្វើសមាហរណកម្មត្រឡប់ចូលក្នុងគ្រួសារនិងសហគមន៍វិញ ក្នុងករណីចាំបាច់ ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ អាចទំនាក់ទំនងមកអគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនដើម្បីជួយសម្របសម្រួល។

### ៦. កិច្ចសហប្រតិបត្តិការអន្តរជាតិ

អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវបន្តបើកទូលាយកិច្ចសហប្រតិបត្តិការទ្វេភាគី ពហុភាគីជាមួយប្រទេសជិតខាង ក៏ដូចជាអង្គការអន្តរជាតិសំខាន់ៗ ដើម្បីក្តាប់ជាប់និន្នាការប្រែប្រួលតាមដំណាក់កាលនីមួយៗ ក្តាប់បានអំពីខ្សែរយៈទំនាក់ទំនង និងបែបផែនសកម្មភាពរបស់ក្រុមឧក្រិដ្ឋជនគ្រឿងញៀន សំដៅមានភាពម្ចាស់ការដាក់ចេញវិធានការទប់ស្កាត់ពីចម្ងាយ និង/ឬធ្វើការបង្ក្រាបបានទាន់ពេល ក្នុងនោះត្រូវយកចិត្តទុកដាក់ទាំងកិច្ចសហប្រតិបត្តិការថ្នាក់ជំនាញនិងមន្ត្រីការិយាល័យទំនាក់ទំនងព្រំដែន (BLO) ដែលឈរជើងតាមព្រំដែន ព្រមទាំងលើកកម្ពស់សមត្ថភាពមន្ត្រីជំនាញ និងទទួលបានការគាំទ្រទាំងស្មារតី ឧបករណ៍ និងសម្ភារបច្ចេកទេស ក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀន។

អគ្គស្នងការដ្ឋាននគរបាលជាតិ ត្រូវបើកទូលាយកិច្ចសហប្រតិបត្តិការផ្លាស់ប្តូរព័ត៌មាន និង/ឬព័ត៌មានតាមករណីនីមួយៗ ជាមួយការិយាល័យអង្គការសហប្រជាជាតិទទួលបន្ទុកគ្រឿងញៀននិងបទឧក្រិដ្ឋ (UNODC) និងអង្គការឧក្រិដ្ឋកម្មនគរបាលអន្តរជាតិ (INTERPOL) និងជាមួយស្ថាប័នអនុវត្តច្បាប់នៃបណ្តាប្រទេសនានា ជាពិសេសបណ្តាប្រទេសដែលជាប្រភពនៃការនាំចូលគ្រឿងញៀនឆ្លងកាត់កម្ពុជា ដើម្បីមានវិធានការក្នុងការបង្ក្រាបអង្គការចាត់តាំងឬបណ្តាញជួញដូរគ្រឿងញៀនជាអន្តរជាតិឱ្យដល់ឫសគល់។

## III. ការចាត់តាំងអនុវត្ត

ដើម្បីអនុវត្តផែនការស្តីពីយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី១០ឱ្យមានប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព ចាំបាច់ត្រូវមានការចាត់តាំងអនុវត្តដូចខាងក្រោម៖

១. គណៈបញ្ជាការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់នេះដឹកនាំដោយ ឯកឧត្តម សន្តិបណ្ឌិត **នេត សាវឿន** ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន **ជាប្រធាន** និងឯកឧត្តមអភិសន្តិបណ្ឌិត **ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ **ជាអនុប្រធាន**។

២. គណៈបញ្ជាការដឹកនាំយុទ្ធនាការ អាចពិនិត្យនិងធ្វើបច្ចុប្បន្នភាពឡើងវិញនូវសមាសភាពមួយចំនួនរបស់គណៈកម្មការចម្រុះនិងលេខាធិការដ្ឋាន ដូចបានកំណត់ក្នុងសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ៣៩ សសរ ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការបង្កើតគណៈបញ្ជាការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់។

៣. គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ត្រូវកសាងផែនការដាក់ស្តែងតាមវិស័យនិងតាមភូមិសាស្ត្រនីមួយៗ តាមដែនសមត្ថកិច្ចរៀងៗខ្លួន ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

៤. ត្រូវមានវិធានការលើកសរសើរ ជូនរង្វាន់សមស្របដល់បណ្ដាអង្គភាព និងបុគ្គលដែលមានស្នាដៃល្អក្នុងការងារបង្ការ ទប់ស្កាត់ និងបង្ក្រាបគ្រឿងញៀន ព្រមទាំងមានវិធានការអនុវត្តវិន័យ ឬវិធានការច្បាប់យ៉ាងម៉ឺងម៉ាត់ចំពោះមន្ត្រីដែលមានជាប់ពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន។

ទទួលបានផែនការនេះ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ក្រសួងមហាផ្ទៃ ក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត និងជាគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្តទាំងអស់ ត្រូវចាត់តាំងអនុវត្តប្រកបដោយស្មារតីទទួលខុសត្រូវនិងមានប្រសិទ្ធភាពខ្ពស់។

ថ្ងៃ សុក្រ ១០ កើត ខែ មាឃ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី ៧ ខែ កុម្ភៈ ឆ្នាំ ២០២៥

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**